**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក
ភាគីដាក់ឯកសារ: មេធាវីការពារក្តីអ្នកស្រី អៀង ធីរិទ្ធ
ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល
ភាសាដើម: អង់គ្លេស
កាលបរិច្ឆេទឯកសារ: ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១១

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 01-Dec-2011, 14:17
CMS/CFO: Phok Chanthan

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ
ចំណាត់ថ្នាក់ឯកសារដោយ អង្គជំនុំជម្រះ : **សាធារណៈ/Public**
ឋានៈនៃចំណាត់ថ្នាក់ឯកសារ
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះ
អាសន្ន:
ឈ្មោះមន្ត្រីកត់ត្រា:
ហត្ថលេខា:

---

**ចម្លើយតបរបស់មេធាវីការពារក្តីលោកស្រី អៀង ធីរិទ្ធ ទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ២០១១**

---

**មេធាវីជនជាប់ចោទ អៀង ធីរិទ្ធ:**

ផាត់ ពៅស៊ាង
Diana ELLIS, QC

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**

ពេជ អង្គ

**ចៅក្រមអង្គជំនុំជម្រះតុលាការកំពូល:**

**ចៅក្រម គង់ ស្រីម ជាប្រធាន**
**ចៅក្រម Motoo Noguchi**
**ចៅក្រម Agniezska KLONOWIECKAMILART**
**ចៅក្រម** Chandra Nihal JAYASINGHE

Elisabeth SIMONNEAU FORT

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម ស៊ិន រិទ្ធិ

ចៅក្រម ម៉ុង មុន្នីចរិយា

ចៅក្រម យ៉ា ណារិន

Florence MUMBA

<u>សហព្រះរាជអាជ្ញា៖</u>

ជា លាង

Andrew CAYLEY

# I សេចក្ដីផ្ដើម

1. នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្ដីសម្រេចលើសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ ("សេចក្ដីសម្រេច")[1]។ តាមរយៈសេចក្ដីសម្រេចជាឯកច្ឆន្ទរបស់អង្គជំនុំជម្រះសាលាដំបូង អៀង ធីរិទ្ធ (ចុងបណ្ដឹងសាទុក្ខ) ត្រូវបានសម្រេចថាមិនមានសម្បទាក្នុងការចូលរួមសវនាការនោះទេ។ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឲ្យបំបែកបទចោទប្រឆាំងលើជនជាប់ចោទ ចេញពីដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង០០២ ដោយអនុលោមទៅតាមវិធាន៨៩ *ស្ទួន*ពីរ នៃវិធានផ្ទៃក្នុង និងបានប្រកាសឲ្យផ្អាកកិច្ចដំណើរការនីតិវិធីប្រឆាំងលើរូបគាត់។ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឲ្យដោះលែងជនជាប់ចោទ ដោយបង្គាប់ឲ្យជនជាប់ចោទត្រូវជូនដំណឹងដល់អង្គជំនុំជម្រះ មុននឹងប្ដូរអាសយដ្ឋានទៅកន្លែងផ្សេង[2]។ សហព្រះរាជអាជ្ញា ("ម្ចាស់បណ្ដឹងសាទុក្ខ") បានដាក់បណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចនេះ កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១១ ("បណ្ដឹងសាទុក្ខ")[3] អនុលោមតាមវិធាន ៨២(៦), ១០៤, ១០៥, ១០៦(២) និង១០៧ នៃវិធានផ្ទៃក្នុង និងបានដាក់សំណើមួយជាមួយគ្នានោះដែរ សុំឲ្យផ្អាកការដោះលែងចុងបណ្ដឹងសាទុក្ខ[4]។

2. នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១១ ប្រធានអង្គជំនុំជម្រះតុលាការកំពូល បានផ្អាកការដោះលែងចុងបណ្ដឹងសាទុក្ខ រហូតដល់ពេលអង្គជំនុំជម្រះតុលាការកំពូលសម្រេចលើបណ្ដឹងសាទុក្ខ។ បន្ទាប់មកអង្គជំនុំជម្រះតុលាការកំពូល បានចេញសេចក្ដីណែនាំទាក់ទងនឹងការដាក់ឯកសារនានាបន្ថែម[5]។ នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ ម្ចាស់បណ្ដឹងឧទ្ធរណ៍បានដាក់សារណាបន្ថែមលើបណ្ដឹងសាទុក្ខទាក់ទងនឹងការដោះលែងចុងបណ្ដឹងសាទុក្ខ[6]។

---

[1] អ.ជ.ស.ដ, សេចក្ដីសម្រេចលើសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារ E138 (សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង)។

[2] *ដូចជើងទំព័រខាងលើ* ទំព័រ២៩-៣០។

[3] ការិយាល័យសហព្រះរាជអាជ្ញា បណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ចុះថ្ងៃទី ១៨ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារ E138/1/1។

[4] ការិយាល័យសហព្រះរាជអាជ្ញា សំណើរបស់សហព្រះរាជអាជ្ញា សុំផ្អាកការដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ចុះថ្ងៃទី១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារ E138/1/2។

[5] អ.ជ.ត.ក, សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំដាក់សារណាបន្ថែម និងសេចក្ដីណែនាំពាក់ព័ន្ធនឹងការដាក់បណ្ដឹងសាទុក្ខ ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារ E138/1/3។

[6] ការិយាល័យសហព្រះរាជអាជ្ញា, សេចក្ដីសន្និដ្ឋានបន្ថែមរបស់សហព្រះរាជអាជ្ញាលើបណ្ដឹងសាទុក្ខពាក់ព័ន្ធនឹងការដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារ E138/1/4។

3. ដោយផ្អែកលើមូលហេតុដែលបានលើកឡើងខាងក្រោម មេធាវីការពារក្តីសូមស្នើសុំថា៖

i) បណ្តឹងសាទុក្ខមិនអាចទទួលយកបាន អនុលោមតាមវិធាន១០៤(៤)(ក) ដោយសារតែសេចក្តីសម្រេចមិនបានបញ្ចប់ដំណើរការនីតិវិធីយ៉ាងមានប្រសិទ្ធភាពនោះទេ។

ii) មិនត្រូវចាត់ទុកសេចក្តីសម្រេចជាមោឃៈទេ ដោយសារតែអង្គជំនុំជម្រះសាលាដំបូងមិនបានភ័ន្តច្រឡំអង្គច្បាប់ ដែលធ្វើឱ្យអសុពលភាពសេចក្តីសម្រេចនោះទេ ឬ ភ័ន្តច្រឡំអង្គហេតុ ដែលធ្វើឱ្យមានភាពមិនយុត្តិធម៌នោះទេ ឬកំហុសក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ដែលនាំឱ្យខូចប្រយោជន៍ដល់ម្ចាស់បណ្តឹងឧទ្ធរណ៍ (វិធាន ១០៥(២)) នោះទេ។

iii) បន្ថែមពីលើនេះ អង្គជំនុំជម្រះសាលាដំបូងមិនបានភ័ន្តច្រឡំអង្គច្បាប់ ឬកំហុសដែលអាចមើលឃើញជាក់ស្តែង ក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ថាតើខ្លួនត្រូវសម្រេចយ៉ាងណាពាក់ព័ន្ធទៅនឹងការបន្តនីតិវិធីទៅមុខទៀត នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងមិនអាចរកសំឡេងភាគច្រើន ដើម្បីសម្រេចអំពីលក្ខខណ្ឌដែលត្រូវអនុវត្តចំពោះចុងបណ្តឹងសាទុក្ខនៅពេលដែលគាត់ត្រូវបានដោះលែង។

iv) ផ្អែកលើមូលដ្ឋាននេះ អង្គជំនុំជម្រះតុលាការកំពូល គួរតម្កល់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង និងបង្គាប់ឱ្យដោះលែងចុងបណ្តឹងសាទុក្ខ ដោយគ្មានលក្ខខណ្ឌ។

v) បន្ថែមពីលើនេះ តុលាការកំពូលគួរបង្គាប់ថា ការផ្អាកដំណើរការនីតិវិធី នឹងនាំឱ្យបញ្ឈប់ឬបញ្ចប់ដំណើរការនីតិវិធីប្រឆាំងនឹងចុងបណ្តឹងសាទុក្ខ។

## II សាវតារទាក់ទងនឹងសំអាងហេតុនៃការមិនមានសម្បទាក្នុងការចូលរួមសវនាការ

### 2.1 របាយការណ៍របស់អ្នកជំនាញ

4. ដើម្បីវាយតម្លៃលើសម្បទាក្នុងការចូលរួមសវនាការរបស់ចុងបណ្តឹងសាទុក្ខ អង្គជំនុំជម្រះសាលាដំបូងបានចាត់តាំងសាស្ត្រាចារ្យ Campbell ដែលជាវេជ្ជបណ្ឌិតជំនាញខាងព្យាបាលថែទាំងជំងឺមនុស្សចាស់ ដើម្បីផ្តល់របាយការណ៍[7]។ ក្រោយពីបានទទួលរបាយការណ៍របស់អ្នកជំនាញ (របាយការណ៍)[8] និងដោយមានសំណើសុំរបស់សហព្រះរាជអាជ្ញា[9] អង្គជំនុំជម្រះសាលាដំបូងបាន

---

[7] អ.ជ.ស.ដ, ដីកាចាត់តាំងអ្នកជំនាញ ចុះថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១១ ឯកសារ E62/3។

[8] របាយការណ៍ដែលបានរៀបចំឡើងដើម្បីជាការឆ្លើយតបទៅនឹងដីកាចាត់តាំងអ្នកជំនាញរបស់អង្គជំនុំជម្រះសាលាដំបូង E62/3, Geriatric Expert Report អ្នកស្រី អៀង ធីរិទ្ធ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ E62/3/6 ("របាយការណ៍របស់សាស្ត្រាចារ្យ Campbell")។

[9] ការិយាល័យសហព្រះរាជអាជ្ញា, ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងរបាយការណ៍អ្នកជំនាញផ្នែកមនុស្សចាស់អ្នកស្រី អៀង ធីរិទ្ធ ជនជាប់ចោទ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១១ ឯកសារ E62/3/6/2។

ចាត់តាំង "អ្នកជំនាញផ្នែកវិកលចរិត" បន្ថែមបួនរូប ដើម្បីផ្តល់របាយការណ៍រួម ដើម្បីបំពេញបន្ថែមទៅនឹងរបាយការណ៍របស់សាស្ត្រាចារ្យ Campbell[10]។ សាស្ត្រាចារ្យ Campbell បានផ្តល់សេចក្តីបន្ថែមទៅនឹងរបាយការណ៍កាលពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១១[11] និងអ្នកជំនាញផ្នែកវិកលចរិតបានដាក់របាយការណ៍រួមរបស់ពួកគាត់ នៅថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១១[12]។ ជាសង្ខេប សាស្ត្រាចារ្យ Campbell បានសន្និដ្ឋាននៅក្នុងរបាយការណ៍របស់គាត់ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១១ ថា ដោយផ្អែកតាមប្រវត្តិជំងឺ ការពិនិត្យកោសល្យវិច័យ ស៊ីធីស្កេនផ្នែកក្បាល និងការធ្វើតេស្តឈាមរបស់ចុងបណ្តឹងសាទុក្ខ បានបង្ហាញឲ្យឃើញថា គាត់បានទទួលរងនូវ "ការចុះខ្សោយដំណើរការខួរក្បាលទូទៅ ជាពិសេសនៅក្នុងផ្នែកអង្គចងចាំ ការនិយាយស្តី ការបកស្រាយ ឬការពន្យល់ និងមុខងារខួរក្បាលខាងលើផ្នែកខាងមុខ ដែលស្របជាមួយនឹងការវង្វេងស្មារតី"[13] ដែលជាដំបូងកើតចេញដោយសារតែជំងឺភ្លេចភ្លាំងដោយសារតែវ័យចាស់ជរា[14]។ គាត់បានលើកឡើង "មានជំងឺវង្វេងស្មារតីធ្ងន់ធ្ងរកម្រិតមធ្យម" ដែលប៉ះពាល់ដល់លទ្ធភាពក្នុងការយល់អំពីសំណួរទាំងឡាយ ក្នុងការអនុវត្តតាមការណែនាំ ក្នុងការរំឭកឡើងវិញពីហេតុការណ៍នានា ក្នុងការប្រមូលផ្តុំអារម្មណ៍ និងក្នុងការរក្សាការគិតឲ្យស៊ីសង្វាក់គ្នា[15]។

5. សាស្ត្រាចារ្យCampbell បានពិចារណាថា របបថ្នាំរបស់ចុងបណ្តឹងសាទុក្ខ អាចជាចំណែកធ្វើឲ្យចុះខ្សោយដំណើរការខួរក្បាលរបស់គាត់ និងបានណែនាំឲ្យកាត់បន្ថយការប្រើឱសថចំនួនបីមុខបន្តិចម្តងៗ ក្នុងចំណោមឱសថដែលមានក្នុងវេជ្ជបញ្ជា ដើម្បីពិនិត្យមើលថាតើស្ថានភាពរបស់គាត់មានលក្ខណៈល្អប្រសើរដែរ ឬយ៉ាងណា[16]។ ការកាត់បន្ថយការប្រើឱសថនេះ ចាប់ផ្តើមដំបូងចំពោះថ្នាំbenzodiazepine ចំនួនពីរមុខ និងបន្ទាប់មកកាត់បន្ថយថ្នាំព្យាបាលរោគ

---

[10] វេជ្ជបណ្ឌិត ហួត លីណា, វេជ្ជបណ្ឌិត កើត ឈុនលី, វេជ្ជបណ្ឌិត Seena Fazel និងវេជ្ជបណ្ឌិត Calvin Fones Soon Leung។ សូមមើល អ.ជ.ស.ដ, ដីកាចាត់តាំងអ្នកជំនាញ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១១ ឯកសារ E111។

[11] របាយការណ៍វាយតម្លៃបន្ថែមពាក់ព័ន្ធនឹងលោកស្រី អៀង ធីរិទ្ធ អនុលោមតាមដីកាចាត់តាំងអ្នកជំនាញ E62/3 របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១១, ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១១ ឯកសារ E62/3/12 ("របាយការណ៍វាយតម្លៃរបស់សាស្ត្រាចារ្យ Campbell")។

[12] របាយការណ៍អ្នកជំនាញរៀបចំឡើងដើម្បីឆ្លើយតបទៅនឹងដីកាចាត់តាំងអ្នកជំនាញ E111 ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១១ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ៩ ខែ តុលា ឆ្នាំ ២០១១ ឯកសារ E111/8 ("របាយការណ៍អ្នកជំនាញផ្នែកវិកលវិទ្យា")។

[13] របាយការណ៍សាស្ត្រាចារ្យ Campbell កថាខណ្ឌ២៨។

[14] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ៣២។

[15] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ៣៥។

[16] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ៤២-៤៥។

វិកលចរិត។ ចុងបណ្តឹងសាទុក្ខ ត្រូវបានវាយតម្លៃជាបន្តបន្ទាប់ដោយសាស្ត្រាចារ្យ Campbell ដោយមានជំនួយពីវេជ្ជបណ្ឌិត ចក់ ធីតា។ ពួកគាត់បានសន្និដ្ឋានថា ការចុះខ្សោយដំណើរការខួរក្បាលរបស់គាត់ មិនបានបង្ហាញភាពប្រសើរឡើងនោះទេ ដូច្នេះគាត់នៅតែមិនមានសមត្ថភាពដើម្បីចូលរួមក្នុងការការពារក្តីរបស់គាត់បានឡើយ[17]។ សាស្ត្រាចារ្យ Campbell បានបញ្ជាក់ច្បាស់លើមតិយោបល់ទាំងនេះ នៅពេលគាត់បានផ្តល់ភស្តុតាង នៅសវនាការមុនអង្គសេចក្តីទាក់ទងនឹងសម្បទារបស់ចុងបណ្តឹងសាទុក្ខ ក្នុងការចូលរួមសវនាការចាប់ពីថ្ងៃទី២៩ ខែសីហា រហូតដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១១[18]។

6. នៅថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១១ ក្រោយពីមានការវាយតម្លៃជារួមលើចុងបណ្តឹងសាទុក្ខ អ្នកជំនាញផ្នែកវិកលចរិតបានដាក់របាយការណ៍រួមរបស់គាត់ ដោយបានសន្និដ្ឋានថា ចុងបណ្តឹងសាទុក្ខ បានទទួលរងនូវការបាត់បង់សមត្ថភាពផ្នែកបញ្ញាស្មារតី ដោយការចុះខ្សោយកម្រិតមធ្យមនូវការចងចាំ និងការចុះខ្សោយនៃសមត្ថភាពសតិបញ្ញាដទៃទៀត ពីកម្រិតតិចតួចរហូតដល់កម្រិតមធ្យម[19]។ ពួកគាត់បានលើកឡើងថា ស៊ីធីស្កេនផ្នែកក្បាលនៅក្នុងឆ្នាំ២០០៧ ឆ្នាំ២០០៩ និងឆ្នាំ២០១១ បានបង្ហាញការកើនឡើងនៃភាពរួញខួរក្បាលជាទូទៅ ដែលស្របទៅនឹងការវិភាគរោគវិជ្ជសាស្ត្រលើការបាត់បង់សមត្ថភាពផ្នែកបញ្ញាស្មារតី[20]។ ពួកគាត់បានយល់ស្របជាមួយសាស្ត្រាចារ្យ Campbell ថា ការវិភាគរោគវិជ្ជសាស្ត្រ គឺទំនងជាជំងឺភ្លេចភ្លាំង ដោយសារតែវ័យចាស់ជរា[21] និងយល់ស្របថា ចុងបណ្តឹងសាទុក្ខ ស្ថិតនៅត្រង់ដំណាក់កាលទី ៥ លើតារាងដែលមាន៧ចំណុច (ការចុះថយនៃសតិបញ្ញាកម្រិតមធ្យម)[22]។ អ្នកជំនាញផ្នែកវិកលចរិត ក៏បានយល់ស្របគ្នាជាឯកច្ឆន្ទថា ចុងបណ្តឹងសាទុក្ខមិនមានសមត្ថភាពយល់ដឹងគ្រប់គ្រាន់អំពីដំណើរការនីតិវិធីតុលាការ ឬប្រឹក្សាជាមួយមេធាវីរបស់ខ្លួនទេ ហេតុដូច្នេះពួកគាត់យល់ឃើញជាស្ថាពរថា គាត់មិនមានសម្បទា

---

[17] របាយការណ៍វាយតម្លៃរបស់សាស្ត្រាចារ្យ Campbell កថាខណ្ឌ៦ និង៨។

[18] សូមមើលប្រតិចារឹកសវនាការស្តីពីកាយសម្បទារបស់ជនជាប់ចោទ ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១១ ឯកសារ E1/8.1។ ប្រតិចារឹកសវនាការស្តីពីកាយសម្បទារបស់ជនជាប់ចោទ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១១ ឯកសារ E1/9.1។ ប្រតិចារឹកសវនាការស្តីពីកាយសម្បទារបស់ជនជាប់ចោទ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១១ ឯកសារ E1/10.1។

[19] របាយការណ៍អ្នកជំនាញផ្នែកវិកលវិទ្យា កថាខណ្ឌ២៧។

[20] របាយការណ៍អ្នកជំនាញផ្នែកវិកលវិទ្យា កថាខណ្ឌ៣៥។

[21] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ៣៦។

[22] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ៣៦។

គ្រប់គ្រាន់ក្នុងការចូលរួមសវនាការទេ[23]។ សំអាងហេតុសំខាន់របស់ពួកគាត់ ត្រូវបានរៀបរាប់យ៉ាងក្បោះក្បាយ នៅកថាខណ្ឌ៤០ ដល់កថាខណ្ឌ៥១ នៃសេចក្តីសម្រេច។

7. អ្នកជំនាញពីររូបក្នុងចំណោមអ្នកជំនាញផ្សេងទៀត វេជ្ជបណ្ឌិត ហួត លីណា និង Seen FAZEL បានផ្តល់ភ័ស្តុតាងជូនដល់អង្គជំនុំជម្រះសាលាដំបូង នៅសវនាការបន្ថែមលើសម្បទារបស់ចុងចោទ បណ្តឹងសាទុក្ខក្នុងការចូលរួមសវនាការ កាលពីថ្ងៃទី១៩ និងទី២០ ខែតុលា ឆ្នាំ២០១១[24]។ ពួកគាត់បានលើកឡើងជាច្រើនសានូវសេចក្តីសន្និដ្ឋានក្នុងរបាយការណ៍រួម និងបានគូសបញ្ជាក់លក្ខណៈវិវឌ្ឍនៃជំងឺ ដោយបានផ្តល់មតិយោបល់អំពីរបៀប នៃការបង្ហាញលក្ខណៈទូទៅតាមបែបវិជ្ជសាស្ត្រនៃជំងឺ "ការចុះជាលំដាប់" និងការពិតដែលថា ជំងឺភ្លេចភ្លាំងដោយសារតែវ័យចាស់ជរាគឺមិនមែនជាទម្រង់នៃជំងឺបាត់បង់សមត្ថភាពផ្នែកបញ្ញាស្មារតីដែលអាចព្យាបាលបាន ឬអាចវិលត្រលប់ទៅជាសភាពធម្មតាវិញនោះទេ[25]។

## 2.2 សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង

8. អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើភ័ស្តុតាង និងបានកត់សម្គាល់ថា អ្នកជំនាញគ្រប់រូបសុទ្ធតែយល់ស្របគ្នាថា ចុងបណ្តឹងសាទុក្ខមានជំងឺបាត់បង់សមត្ថភាពផ្នែកបញ្ញាស្មារតី ដែលទំនងជាបណ្តាលមកពីជំងឺភ្លេចភ្លាំង ដោយសារតែវ័យចាស់ជរា និងមានការចុះខ្សោយបញ្ញាស្មារតីគួរឲ្យកត់សម្គាល់ ជាពិសេសពាក់ព័ន្ធនឹងការចងចាំរយៈពេលខ្លី និងការចងចាំរយៈពេលវែងរបស់គាត់[26]។ ពួកគាត់ក៏បានកត់សម្គាល់ដែរថា ម្ចាស់បណ្តឹងឧទ្ធរណ៍ បានទទួលស្គាល់ថា ចុងបណ្តឹងសាទុក្ខ មានជំងឺចុះខ្សោយការចងចាំគួរឲ្យកត់សម្គាល់[27]។ បន្ថែមពីលើនេះ អង្គជំនុំជម្រះបានបង្ហាញថា អ្នកជំនាញគ្រប់រូបបានពិចារណាអំពីលទ្ធភាពដែលថា ចុងបណ្តឹងសាទុក្ខអាចមាន

---

[23] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ៤៣, ៤៥ និង៥១។

[24] សូមមើលប្រតិចារឹកសវនាការស្តីពីការកំណត់ជាក់លាក់នូវសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ ចុះថ្ងៃ ១៩ ខែ តុលា ឆ្នាំ ២០១១ ឯកសារ E1/11.1។ ប្រតិចារឹកសវនាការស្តីពីការកំណត់ជាក់លាក់នូវសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ ឯកសារE1/12.1។

[25] ប្រតិចារឹក ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១១ ទំព័រ១២៩ និងទំព័រ១៣០។

[26] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ៥២។

[27] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ១៥ យោងទៅលើប្រតិចារឹក ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ ទំព័រ១០៧។

ចេតនាធ្វើពុតជាមានការចុះខ្សោយសតិបញ្ញាស្មារតី ប៉ុន្តែពួកគាត់មិនគិតថា ចុងបណ្ដឹងសាទុក្ខមិនទំនងជាធ្វើពុតនោះទេ។ ការធ្វើតេស្ត ក៏បានពិចារណាលើកត្តានេះផងដែរ[28]។

9. អង្គជំនុំជម្រះសាលាដំបូង បានយល់ស្របជាមួយអ្នកជំនាញថា ការបាត់បង់ការចងចាំរយៈពេលខ្លី និងរយៈពេលវែងរបស់ចុងបណ្ដឹងសាទុក្ខ ច្បាស់ជាធ្វើឱ្យចុងបណ្ដឹងសាទុក្ខមិនអាចយល់ដឹងអំពីការប្រព្រឹត្តទៅនៃកិច្ចដំណើរការនីតិវិធីឱ្យបានគ្រប់គ្រាន់ ដើម្បីអាចឱ្យគាត់ណែនាំមេធាវីការពារក្តីរបស់គាត់ឱ្យបានគ្រប់ជ្រុងជ្រោយ និងចូលរួមក្នុងការការពារក្តីរបស់គាត់ឱ្យមានប្រសិទ្ធភាពបាន ដូចនេះចុងបណ្ដឹងសាទុក្ខ មិនអាចអនុវត្តសិទ្ធិជាសារវ័ន្តរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌នោះទេ[29]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះបានប្រកាសថា ចុងបណ្ដឹងសាទុក្ខមិនមានសម្បទាក្នុងការចូលរួមសវនាការ។ អង្គជំនុំជម្រះ បង្គាប់ឱ្យបំបែកសំណុំរឿងចុងបណ្ដឹងសាទុក្ខចេញពីជនជាប់ចោទផ្សេងទៀត និងផ្អាកកិច្ចដំណើរការនីតិវិធីប្រឆាំងលើចុងបណ្ដឹងសាទុក្ខ។ អង្គជំនុំជម្រះបានសម្រេចជាឯកច្ឆន្ទថា លែងមានមូលដ្ឋានណាមួយដើម្បីឃុំខ្លួនចុងបណ្ដឹងសាទុក្ខទៀតហើយ[30]។

10. ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះសាលាដំបូង បានខ្វែងមតិយោបល់ចំពោះផលវិបាកដែលកើតចេញពីសេចក្តីសម្រេចរបស់ខ្លួន។ ចៅក្រមជាតិបីរូប យល់ឃើញថា ចុងបណ្ដឹងសាទុក្ខត្រូវឃុំខ្លួនជាចាំបាច់នៅក្នុងមន្ទីរពេទ្យ និងបន្តព្យាបាលក្នុងមួយរយៈពេលដែលកំណត់[31] ខណៈដែលចៅក្រមអន្តរជាតិយល់ឃើញថា ចុងបណ្ដឹងសាទុក្ខត្រូវតែដោះលែងដោយគ្មានលក្ខខណ្ឌ[32]។ ថ្វីបើមានការខ្វែងយោបល់ខាងក្នុងបែបនេះក្តី ក៏អង្គជំនុំជម្រះសាលាដំបូងបានយល់ស្របជាឯកច្ឆន្ទថា អវត្តមាននៃការព្រមព្រៀង ថាតើអង្គជំនុំជម្រះមាន ឬមិនមានយុត្តាធិការដាក់លក្ខខណ្ឌនៅពេលដោះលែង ក៏ចុងបណ្ដឹងសាទុក្ខគួរតែដោះលែងដោយគ្មានលក្ខខណ្ឌ លើកលែងតែការបង្គាប់ឱ្យជូនដំណឹងដល់អង្គជំនុំជម្រះ មុននឹងប្តូរអាសយដ្ឋានទៅកន្លែងផ្សេងទៀតតែប៉ុណ្ណោះ[33]។

---

[28] របាយការណ៍អ្នកជំនាញផ្នែកវិកលវិទ្យា កថាខណ្ឌ៣៥។ ប្រតិចារឹកចុះថ្ងៃទី២៩ ខែ សីហា ឆ្នាំ ២០១១ ទំព័រ១៣៨។ ប្រតិចារឹកចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១១ ទំព័រ៥៥។

[29] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ៥៩។

[30] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ៦១, ៦២ និង៧៧។

[31] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ៦៣-៦៧។

[32] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ៦៩-៧៧។

[33] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ៨១-៨២ និងសំអាងហេតុ។

## III បទប្បញ្ញត្តិច្បាប់

### 3.1 ភាពអាចទទួលយកបាន និងមូលដ្ឋាននៃបណ្តឹងសាទុក្ខ

11. វិធាន ១០៤(៤) នៃវិធានផ្ទៃក្នុង ចែងថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដូចខាងក្រោមត្រូវបានបើកផ្លូវឲ្យប្តឹងសាទុក្ខភ្លាមៗ៖

(ក) សេចក្តីសម្រេចដែលមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី។

(ខ) សេចក្តីសម្រេចអំពីការឃុំខ្លួន និងការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ អនុលោមតាមវិធាន ៨២ នៃវិធានផ្ទៃក្នុង។

12. លើសពីនេះទៀត អនុលោមតាមវិធាន ១០៤(១) និងវិធាន ១០៥ នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះតុលាការកំពូលត្រូវសម្រេចលើបណ្តឹងសាទុក្ខ ជំទាស់ទៅនឹងសាលក្រមលើអង្គសេចក្តី ឬសេចក្តីសម្រេចនៃអង្គជំនុំជម្រះសាលាដំបូង ដោយផ្អែកលើមូលដ្ឋាន ដូចខាងក្រោម៖

(ក) កំហុសលើអង្គច្បាប់ ដែលនាំឲ្យមោឃៈ សាលក្រមលើអង្គសេចក្តី ឬ សេចក្តីសម្រេចនោះ។

(ខ) កំហុសនៃអង្គហេតុ ដែលនាំឲ្យសាលក្រមលើអង្គសេចក្តី ឬសេចក្តីសម្រេចនោះមានភាពមិនយុត្តិធម៌ ឬ

(គ) ការភ័ន្តច្រឡំដែលស្តែងចេញពីការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលនាំឲ្យប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្តឹងសាទុក្ខ។

### 3.2 បទប្បញ្ញត្តិច្បាប់ពាក់ព័ន្ធ

13. បទប្បញ្ញត្តិពាក់ព័ន្ធមានដូចខាងក្រោមនេះ៖

**មាត្រា ៤ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជា - ការសម្រេចសេចក្តី**

១. ចៅក្រមត្រូវព្យាយាមឈានទៅដល់ការឯកភាពគ្នាជាឯកច្ឆន្ទ នៅក្នុងការសម្រេចសេចក្តីរបស់ខ្លួន។ ប្រសិនបើមិនអាចទទួលបានការឯកភាពគ្នាជាឯកច្ឆន្ទទេ ត្រូវអនុវត្តរូបមន្តខាងក្រោមនេះ៖

ក-ការសម្រេចសេចក្តីរបស់សាលាដំបូងតម្រូវឲ្យមានសំឡេងឆ្នោតគាំទ្រពីចៅក្រមបួនរូបយ៉ាងតិច។

ខ-ការសម្រេចសេចក្ដីដោយអង្គជំនុំជម្រះវិសាមញ្ញតុលាការកំពូល តម្រូវឱ្យមានសំឡេងឆ្នោតគាំទ្រពីចៅក្រមប្រាំរូប យ៉ាងតិច។

២. នៅពេលដែលគ្មានការឯកភាពជាឯកច្ឆន្ទទេ ការសម្រេចសេចក្ដីរបស់អង្គជំនុំជម្រះ ត្រូវមានទស្សនៈរបស់មតិភាគច្រើន និងមតិភាគតិច។

**មាត្រា១៣ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជា - សិទ្ធិរបស់ជនជាប់ចោទ**

១. សិទ្ធិរបស់ជនជាប់ចោទ ដែលមានចែងនៅក្នុងមាត្រា១៤ និង១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រូវតែបានគោរពនៅទូទាំងដំណើរការនៃការជំនុំជម្រះក្ដី។ សិទ្ធិបែបនេះជាពិសេស រួមមានសិទ្ធិទទួលបាននូវសវនាការមួយត្រឹមត្រូវ និងជាសាធារណៈ សិទ្ធិត្រូវបានចាត់ទុកថា គ្មានទោសពៃរ៍ រហូតដល់ពេលរកឃើញថាជាប់ពិរុទ្ធ។

**មាត្រា ៣៣ថ្មី នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក**

ប្រសិនបើនីតិវិធី ដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ ឬប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬអនុវត្តនីតិវិធីនោះ [...] គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ។

**មាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា**

ចៅក្រមស៊ើបសួរអាចដាក់ជនត្រូវចោទឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបាន គ្រប់ពេលវេលា ប្រសិនបើជនត្រូវចោទនេះ ត្រូវបានចោទប្រកាន់អំពីបទល្មើសដែលត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារ។

**មាត្រា ៩ នៃកតិកាសញ្ញាអន្តរជាតិ ស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ**

ជនគ្រប់រូបមានសិទ្ធិមានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន។ គ្មានជនណាម្នាក់ ត្រូវបានចាប់ខ្លួន ឬឃុំខ្លួនតាមអំពើចិត្តបានឡើយ។ គ្មានជនណាម្នាក់ ត្រូវដកហូតសេរីភាពបានឡើយ លើកលែងតែមានហេតុផល និងស្របតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់។

**មាត្រា ៨ នៃអនុសញ្ញាស្ដីពីសិទ្ធិមនុស្សអឺរ៉ុបចែងថា ៖**

១. ជនគ្រប់រូបមានសិទ្ធិក្នុងការគោរពចំពោះជីវិតគ្រួសារ និងជីវិតឯកជនរបស់ពួកគេ ផ្ទះសម្បែងរបស់ពួកគេ និងការប្រាស្រ័យទាក់ទងរបស់ពួកគេ...។

## IV ភាពអាចទទួលយកបាននៃបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា

14. មានការអះអាងថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងបង្គាប់ឱ្យដោះលែងចុងបណ្តឹងសាទុក្ខដោយគ្មានលក្ខខណ្ឌ មិនមែនមានន័យស្មើនឹងការបញ្ចប់ដំណើរការនីតិវិធីឡើយ ហេតុដូច្នេះបណ្តឹងសាទុក្ខរបស់ម្ចាស់បណ្តឹងសាទុក្ខ អនុលោមតាមមាត្រា ១០៤(៤)(ក) មិនអាចទទួលយកបានឡើយ។

15. អង្គជំនុំជម្រះសាលាដំបូងបញ្ជាក់យ៉ាងច្បាស់ថា កិច្ចដំណើរការនីតិវិធីត្រូវបានផ្អាក មិនមែនបញ្ចប់ ឬមិនបន្តនោះទេ និងមិនបានយល់ស្របទៅនឹងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីស្នើសុំឱ្យបញ្ឈប់ដំណើរការនីតិវិធីឡើយ[34]។ ដូច្នេះ ទោះបីជាការផ្អាក *ទំនងជា* មានលក្ខណៈអចិន្ត្រៃយ៍ ឬមិនអចិន្ត្រៃយ៍ក៏ដោយ ក៏វាមិននាំឱ្យមានការបញ្ចប់ដំណើរការនីតិវិធីឡើយ[35] ហើយអង្គជំនុំជម្រះនៅតែទទួលបានដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ វចនានុក្រម Black's Law កំណត់និយមន័យពាក្យខាងក្រោមនេះ៖

> **ការផ្អាក** - ១. ការលើកទៅពេលក្រោយ ឬការផ្អាកនៃកិច្ចដំណើរការនីតិវិធី សាលក្រម ឬប្រភេទស្រដៀងគ្នានេះ។ ២. សេចក្តីបង្គាប់ឱ្យផ្អាកកិច្ចដំណើរការនីតិវិធីទាំងអស់ ឬផ្នែកខ្លះ ឬសាលក្រម ដែលចេញមកពីកិច្ចដំណើរការនីតិវិធីនោះ[36]
>
> **ការបញ្ចប់** - ១. អំពើនៃការបញ្ចប់អ្វីមួយ។ ២. ការបញ្ចប់អ្វីមួយដែលកំពុងមានអត្ថិភាព, សេចក្តីបញ្ចប់ ឬការបញ្ឈប់លែងឱ្យមានបន្តទៀត[37]

16. ម្ចាស់បណ្តឹងសាទុក្ខទទួលស្គាល់ថា ដំណើរការនីតិវិធីប្រឆាំងនឹងចុងបណ្តឹងសាទុក្ខ "យ៉ាងហោចណាស់នៅកំពុងតែបន្តទៅមុខដែរ"[38] ហើយថា មានភាពខុសគ្នារវាង "ការផ្អាក" និង "ការបញ្ចប់" ដំណើរការនីតិវិធី ដូចដែលសហព្រះរាជអាជ្ញាបានបញ្ជាក់នៅក្នុងសេចក្តីសន្និដ្ឋានបន្ថែមរបស់ខ្លួនថា "ខណៈដែលកិច្ចដំណើរការនីតិវិធីត្រូវបានផ្អាក ប៉ុន្តែមិនត្រូវបានបញ្ចប់នោះទេ ...[39] និង "ខណៈដែលកិច្ចដំណើរការនីតិវិធីត្រូវបានផ្អាកនៅដំណាក់កាលសវនាការ ម្ចាស់បណ្តឹងសាទុក្ខនៅតែជាភាគីតទល់គ្នាមួយនៅក្នុងដំណើរការនីតិវិធី"[40]។

---

[34] ប្រតិចារឹក សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់មេធាវីការពារក្តី ថ្ងៃទី ២០ ខែ តុលា។

[35] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ៦១, ៦៤ និង៧៨។

[36] Blacks' Law Dictionary (West Group, 2004), បោះពុម្ពលើកទី៨ ទំព័រ ១៤៥៣។

[37] *ដូចជើងទំព័រខាងលើ* ទំព័រ១៥១១។

[38] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា កថាខណ្ឌ១១។

[39] សេចក្តីសន្និដ្ឋានបន្ថែមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៤។

[40] សេចក្តីសន្និដ្ឋានបន្ថែមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៥។

17. លើសពីនេះទៀត ម្ចាស់បណ្តឹងសាទុក្ខនៅតែមានសមត្ថភាពពេញលេញក្នុងការស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងវាយតម្លៃលើជនជាប់ចោទឡើងវិញ និងផ្តល់យោបល់ឲ្យអង្គជំនុំជម្រះនៅ គ្រប់ពេលវេលាទាំងអស់ ហើយដូច្នេះ ដំណើរការនីតិវិធីមិនត្រូវ "បានបញ្ចប់ដោយប្រសិទ្ធភាពឡើយ"។ ជាពិសេស ម្ចាស់បណ្តឹងសាទុក្ខអាចស្នើសុំឲ្យមានការតែងតាំងអ្នកជំនាញបន្ថែម ការពិនិត្យឡើងវិញ ឬការវិនិច្ឆ័យផ្នែកវេជ្ជសាស្ត្របន្ថែមទៀត ដោយយោងលើវិធាន ៣១ និង ៣២ ហើយអង្គជំនុំជម្រះសាលាដំបូងអាចបើកកិច្ចប្រជុំរៀបចំសវនាការនៅពេលណាក៏បាន ស្របតាមវិធាន ៧៩។ ដូច្នេះ "ការផ្អាក" របស់អង្គជំនុំជម្រះសាលាដំបូងមិនមែនមានន័យស្មើនឹង "ការបញ្ចប់" ដំណើរការនីតិវិធីឡើយអនុលោមតាមវិធានផ្ទៃក្នុង ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង។

18. លើសពីនេះទៀត អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ "សហព្រះរាជអាជ្ញាថា សហព្រះរាជអាជ្ញាអាចស្នើសុំឲ្យអង្គជំនុំជម្រះចាត់តាំងអ្នកជំនាញឲ្យធ្វើការវាយតម្លៃ អៀង ធីរិទ្ធ ឡើងវិញតាមរយៈការ..."[41] ដូច្នេះ បង្ហាញឲ្យឃើញថា បញ្ហានេះមិនត្រូវបានបញ្ចប់ដោយការផ្អាកនោះទេ។ ម្ចាស់បណ្តឹងសាទុក្ខអាចបង្កើតនូវ "យន្តការដើម្បីត្រួតពិនិត្យស្ថានភាពសុខភាពរបស់ជនជាប់ចោទជាប្រចាំ" ប្រសិនបើត្រូវបានអនុញ្ញាតឲ្យធ្វើដូច្នេះ ដោយផ្អែកលើសំណើសុំទៅអង្គជំនុំជម្រះសាលាដំបូង។ ប្រសិនបើមានភាពមិនច្បាស់លាស់ ឬភាពស្រពិចស្រពិល ដែលមិនអាចទទួលយកបាន នៅក្នុងពាក្យពេចន៍ដែលអង្គជំនុំជម្រះសាលាដំបូងបានប្រើក្នុងការ "ជូនដំណឹង" បែបនេះដល់ចុងបណ្តឹងសាទុក្ខនោះ កំហុសនេះមិនធ្វើឲ្យប៉ះពាល់ដល់ខ្លឹមសារនៃការផ្តល់សំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូង ឬនាំឲ្យមោឃៈសេចក្តីសម្រេចឡើយ។

## V សារណា

19. មានការអះអាងដោយសេចក្តីគោរពថា ពុំមានមូលដ្ឋានដែលត្រូវធ្វើមោឃៈភាពសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ ហេតុដូច្នេះ ចុងបណ្តឹងសាទុក្ខគួរតែត្រូវបានដោះលែងជាបន្ទាន់ដោយគ្មានលក្ខខណ្ឌ។

### 5.1 ពុំមានកំហុសអង្គច្បាប់ឡើយ

20. ម្ចាស់បណ្តឹងសាទុក្ខអះអាងថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការដោះលែងចុងបណ្តឹងសាទុក្ខដោយគ្មានលក្ខខណ្ឌ បានផ្អែកទៅលើ អង្គច្បាប់ដោយខុសឆ្គង ជាពិសេស ការខកខានពុំបានពិចារណាទៅលើវិធាន ៦៣, ៦៤ និង ៨២ ដែលចែងអំពីការឃុំខ្លួនបណ្តោះ

---

[41] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ទំព័រ៣០។

អាសន្ន និងការងាកចេញពីយុត្តិសាស្ត្រអន្តរជាតិ ទាក់ទិននឹងលទ្ធផលនៃការរកឃើញអំពីភាពពុំមានសម្បទាក្នុងការចូលរួមសវនាការ[42]។

21. ចុងបណ្តឹងសាទុក្ខអះអាងថា ដោយយោងលើហេតុផលដែលបានបញ្ជាក់ខាងក្រោមនេះ អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសអង្គច្បាប់ដែលនាំឱ្យមោឃៈសេចក្តីសម្រេចឡើយ ហើយវាជាការត្រឹមត្រូវក្នុងការសន្និដ្ឋានថា ពុំមានមូលដ្ឋានផ្លូវច្បាប់ក្នុងការឃុំខ្លួនចុងបណ្តឹងសាទុក្ខ នៅក្នុងកាលៈទេសៈដែលដំណើរការនីតិវិធីត្រូវបានផ្អាក ដោយគ្មានមូលហេតុសមស្របថា នឹងមានការជំនុំជម្រះក្តីលើរូបគាត់ឡើងវិញបាននោះ[43]។

22. ចុងបណ្តឹងសាទុក្ខអះអាងថា វិធាន ៦៣ និង ៦៤ អាចអនុវត្តបានចំពោះដំណាក់កាលមុនជំនុំជម្រះក្តី នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត មិនមែនអនុវត្តចំពោះដំណើរការនីតិវិធី នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងឡើយ។ មិនដូចជាវិធាន ៦៤ ដែលចែងយ៉ាងច្បាស់ថា សហចៅក្រមស៊ើបអង្កេតអាចចេញដីកាបង្គាប់ឱ្យដោះលែង "ប្រសិនបើលក្ខខណ្ឌតម្រូវ នៃការឃុំខ្លួនបណ្តោះអាសន្ន ដែល *មានចែងនៅក្នុងវិធាន ៦៣* មិនអនុវត្តបាន" វិធាន ៨២ ពុំបានយោងជាក់លាក់ទៅលើបទប្បញ្ញត្តិនេះឡើយ ប៉ុន្តែវិធាននេះផ្តល់ឱ្យអង្គជំនុំជម្រះសាលាដំបូងនូវឆន្ទានុសិទ្ធិយ៉ាងធំសម្បើមក្នុងការបង្គាប់ឱ្យដោះលែងជនជាប់ចោទ នៅពេលដែលខ្លួនយល់ឃើញថាសមស្រប ដែលតាមការទាញនូវសេចក្តីសន្និដ្ឋាន ត្រូវតែរួមបញ្ចូលនូវស្ថានភាពដែលកិច្ចដំណើរការនីតិវិធីត្រូវបានផ្អាក ឬលើកពេល។

23. សូម្បីអង្គជំនុំជម្រះសាលាដំបូងគួរតែបានពិចារណាលើបទប្បញ្ញត្តិនៃវិធាន ៦៣ និង ៦៤ ដែលមិនអាចទទួលយកបាននោះហើយក៏ដោយ ក៏ការធ្វើដូច្នេះមិននាំឱ្យមោឃៈសេចក្តីសម្រេចរបស់ខ្លួនក្នុងការដោះលែងចុងបណ្តឹងសាទុក្ខ ដែលត្រូវបានធ្វើឡើងដោយផ្អែកលើភស្តុតាងដែលថា ការឃុំខ្លួនរបស់ចុងបណ្តឹងសាទុក្ខអាចជាស្ថានទម្ងន់មួយ ដែលរួមចំណែកដល់ការចុះខ្សោយផ្នែកសតិបញ្ញារបស់គាត់[44]។ លើសពីនេះទៀត មានភាពមិនច្បាស់លាស់ដ៏គួរឱ្យកត់សម្គាល់ចំពោះ ថាតើចុងបណ្តឹងសាទុក្ខនឹងមានលក្ខណៈល្អប្រសើរគ្រប់គ្រាន់ដើម្បីចូលរួមសវនាការ
ឬយ៉ាងណានោះទេ។ ទាំងចៅក្រមជាតិ និងចៅក្រមអន្តរជាតិមិនគាំទ្រឱ្យមានការឃុំខ្លួនបន្តទៀតឡើយ។ ភាពខ្វែងគំនិតគ្នាគឺទៅលើថាតើ ចុងបណ្តឹងសាទុក្ខ គួរតែសម្រាកនៅមន្ទីរពេទ្យជា

---

[42] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា កថាខណ្ឌ៨-១៤។ សេចក្តីសន្និដ្ឋានបន្ថែមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៧-១៨។

[43] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ៦១, ៧២ និង៧៧។

[44] សូមមើលកថាខណ្ឌ៣៨-៤១ នៃចម្លើយតបនេះ។

ចាំបាច់ជាច្រើនខែ ដើម្បីទទួលការព្យាបាល ឬយ៉ាងណា។ វិធាន ៦៣(៣) ចែងអំពីលក្ខខណ្ឌដែលត្រូវ តែបំពេញមុនពេលមានការចេញដីកាឃុំខ្លួនបណ្ដោះអាសន្ន។ ពុំមានលក្ខខណ្ឌដែលកំណត់ឱ្យមានការសម្រាកនៅមន្ទីរពេទ្យជាចាំបាច់សម្រាប់ជនជាប់ចោទ ក្នុងការទទួលបានការព្យាបាលឡើយ។ ចៅក្រមជាតិ នៅក្នុងយោបល់របស់ខ្លួនចំពោះលទ្ធផលដែលគួរកើតចេញមកពីសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង មានឧបាស្រ័យចំពោះមាត្រា ២២៣(១១) នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា[45]។ យើងសូមអះអាងដោយសេចក្ដីគោរពថា មាត្រានេះពាក់ព័ន្ធនឹងចៅក្រមស៊ើបអង្កេត ដែលដាក់ជនត្រូវចោទក្រោមការត្រួតពិនិត្យរបស់តុលាការ និងមិនអាចអនុវត្តបានចំពោះស្ថានភាពកិច្ចការបច្ចុប្បន្ននេះឡើយ។ នៅគ្រប់កាលៈទេសៈទាំងអស់ ការបន្តឃុំខ្លួននឹងរំលោភលើសិទ្ធិរបស់ចុងចោទក្នុងការទទួលបាននូវសេរីភាព និងការជំនុំជម្រះក្ដីប្រកបដោយយុត្តិធម៌ (មាត្រា ៩(៣) ICCPR)[46]។

24. លើសពីនេះទៀត ផ្ទុយទៅនឹងការអះអាងរបស់ម្ចាស់បណ្ដឹងសាទុក្ខ[47] ចុងបណ្ដឹងសាទុក្ខអះអាងថា យុត្តិសាស្ត្រ និងវិធានអន្តរជាតិ ពុំបានបង្ហាញថា លក្ខខណ្ឌតឹងរ៉ឹងគឺជានិយាមឡើយ នៅក្នុងកាលៈទេសៈដែលកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទត្រូវបានផ្អាក ដោយសារតែជនជាប់ចោទពុំមានសម្បទាគ្រប់គ្រាន់ ដើម្បីចូលរួមក្នុងសវនាការ។ ទោះបីជាម្ចាស់បណ្ដឹងសាទុក្ខយោងទៅលើរឿងក្ដី *Dukić*[48] រឿងក្ដី *Talić*[49] រឿងក្ដី *Stanišić*[50] និងរឿងក្ដី *Kovacević*[51] យកមកធ្វើជាឧទាហរណ៍អំពីករណីដែលកិច្ចដំណើរការនីតិវិធីមិនត្រូវបានបញ្ចប់

---

[45] សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ៦៦។

[46] សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ៨០។

[47] បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា កថាខណ្ឌ១៣-១៤។ សូមមើលផងដែរ សេចក្ដីសន្និដ្ឋានបន្ថែមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៨-១៨។

[48] *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង* Djukić សំណុំរឿងលេខIT-96-20-T សេចក្ដីសម្រេចបដិសេធពាក្យសុំដកដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងដីកាសម្រេចដោះលែងបណ្ដោះអាសន្ន ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៩៦។

[49] *រឿងក្ដីរដ្ឋអាជ្ញាតទល់នឹង Talić* សំណុំរឿងលេខIT-99-36-T, សេចក្ដីសម្រេចលើសំណើសុំដោះលែងបណ្ដោះអាសន្នជនជាប់ចោទ Momir Talić ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០០២។

[50] *រឿងក្ដីរដ្ឋអាជ្ញាតទល់នឹង Stanišić* សំណុំរឿងលេខIT-03-69-T, សេចក្ដីសម្រេចលើការដោះលែងបណ្ដោះអាសន្ន ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៨។

[51] *រឿងក្ដីរដ្ឋអាជ្ញាតទល់នឹង Kovacević* សំណុំរឿងលេខIT-01-42/2-I, សំណៅជាសាធារណៈនៃសេចក្ដីសម្រេចលើសម្បទារបស់ជនជាប់ចោទក្នុងការផ្ដល់ចម្លើយ និងចូលរួមក្នុងសវនាការ ចុះថ្ងៃទី ១២ ខែ មេសាឆ្នាំ ២០០៦។

បន្ទាប់ពីការរកឃើញអំពីការពុំមានសម្បទាគ្រប់គ្រាន់យ៉ាងណាក៏ដោយ[52] ក៏មានការអះអាងថា សំអាងនេះមិនបានផ្តល់នូវការគាំទ្រដល់ទឡ្ហីករណ៍ដែលថា អង្គជំនុំជម្រះមានកំហុសផ្នែកអង្គហេតុ នៅក្នុងការធ្វើសេចក្តីសម្រេចរបស់ខ្លួនដោះលែងចុងបណ្តឹងសាទុក្ខពីការឃុំខ្លួនឡើយ។

25. ចុងបណ្តឹងសាទុក្ខ អះអាងថា សេចក្តីសម្រេចដោះលែងជនជាប់ចោទ (ដោយមាន ឬ ដោយគ្មាន លក្ខខណ្ឌ) ក្រោយពីបានរកឃើញថា ជនជាប់ចោទពុំមានសម្បទា ត្រូវធ្វើឡើងដោយផ្អែកលើ ករណីនីមួយៗ ពីព្រោះថា ករណីនីមួយៗនឹងបង្ហាញអង្គហេតុឱ្យឃើញដោយខ្លួនឯង។ ការរក ឃើញបែបនេះបានទទួលស្គាល់នៅក្នុងរឿងក្តី *Talić* ដែលបានលើកឡើងថា នៅពេលវាយតម្លៃ ថាតើជនជាប់ចោទគួរ ឬ ពុំគួរត្រូវដោះលែងនោះ អង្គជំនុំជម្រះសាលាដំបូង ត្រូវ "ផ្តោតលើ ស្ថានភាពជាក់លាក់នៃអ្នកដាក់ពាក្យសុំនីមួយៗ" ហេតុដូច្នេះ បទប្បញ្ញត្តិស្តីពីការដោះលែង បណ្តោះអាសន្ន "មិនអាចអនុវត្ត *ដោយអន្តោមាត់*នោះឡើយ ប៉ុន្តែ ត្រូវយកមកអនុវត្តដោយផ្អែកលើ អង្គហេតុនៃករណីជាក់លាក់នីមួយៗ"[53]។ ដីកាសម្រេចដែលសាលាក្តីអន្តរជាតិបានចេញ ពុំមែនជា "បទដ្ឋាន" មួយឡើយ ពីព្រោះវាគ្រាន់តែផ្តល់ជាការជួយជ្រោមជ្រែង ត្រឹមកម្រិតមួយដែលថា ដីកា សម្រេចទាំងនេះបង្ហាញនូវស្ថានភាព និងសេចក្តីសម្រេចដែលចៅក្រមបានធ្វើឡើងដោយឡែកៗ ពីគ្នា ក្រោយពីបានពិចារណាលើបញ្ហាសុខភាពជាក់លាក់របស់ជនត្រូវចោទ និងសញ្ញាបង្ហាញអំពី ភាពប្រសើរឡើង។

26. ទោះក្នុងករណីណាក៏ដោយ ទាំងរឿងក្តី *Talić* និងរឿងក្តី *Dukić* ចុងចោទមិនត្រូវបានឃុំខ្លួនក្នុង មន្ទីរឃុំឃាំង ឬ ទទួលបានការព្យាបាលនៅក្នុងមន្ទីរពេទ្យឡើយ។ ផ្ទុយទៅវិញ ជនទាំងពីរត្រូវបាន ដោះលែងឱ្យត្រឡប់ទៅលំនៅដ្ឋានរបស់ខ្លួនវិញ បើទោះជាមានភ្ជាប់លក្ខខណ្ឌនៃការដោះលែង ក៏ដោយ[54]។ ដូចដើមបណ្តឹងសាទុក្ខបានលើកឡើងដោយភ័ន្តច្រឡំនៅក្នុងបណ្តឹងសាទុក្ខនេះ អង្គជំនុំ ជម្រះសាលាដំបូងនៃសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ពុំបានស្នើសុំ ឱ្យតម្កល់ការឃុំខ្លួនទុកជាបានការឡើយ ទោះក្នុងករណីណាមួយក៏ដោយ។

27. នេះគឺជាការស្នើឡើងដោយគោរពថា ស្ថានភាពសុខភាពរបស់ចុងបណ្តឹងសាទុក្ខនេះ អាចមាន លក្ខណៈប្លែកពីស្ថានភាពសុខភាពរបស់ជនជាប់ចោទនៅក្នុងរឿងក្តីទាំងឡាយ ដែលដើមបណ្តឹង សាទុក្ខបានចង្អុលយោង។ ជាសំខាន់បំផុតនោះ ជនជាប់ចោទនៅក្នុងរឿងក្តី *Talić* និងរឿងក្តី

---

[52] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា កថាខណ្ឌ១៣។ សេចក្តីសន្និដ្ឋានបន្ថែមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ១០, ១១, ១៣, ១៤។

[53] ករណី *រដ្ឋអាជ្ញា ទល់នឹង* Talić កថាខណ្ឌ ២១។

[54] ករណី *រដ្ឋអាជ្ញា ទល់នឹង* Talić ទំព័រ ១៣-១៤ និងករណី *រដ្ឋអាជ្ញា ទល់នឹង* Djukić ទំព័រ ៤-៥។

*Dukić* មានស្ថានភាពសុខភាពរូបរាងកាយដែលពុំអាចព្យាបាលបាន ពោលគឺជំងឺចុះខ្សោយសតិបញ្ញាជាលំដាប់ ដូចនៅក្នុងរឿងក្ដីនេះ។ រឿងក្ដី *Talić* ក៏អាចមានលក្ខណៈប្លែកពីរឿងក្ដីផ្សេងទៀតដែលបានដកស្រង់ផងដែរ ដែលការដោះលែងបណ្ដោះអាសន្នត្រូវបានស្នើឡើង ក្រោយពីការជំនុំជម្រះក្ដីបានចាប់ផ្ដើម។

28. នៅក្នុងរឿងក្ដី *Stanišić* ទោះបីជាជនជាប់ចោទទទួលការព្យាបាលនៅក្នុងមន្ទីរពេទ្យក៏ដោយ ក៏ជននេះពុំមែនមានជំងឺចុះខ្សោយជាលំដាប់ ពោលគឺ ជំងឺវង្វេងវង្វាន់ឡើយ ហើយក៏គេមានសង្ឃឹមថាជនជាប់ចោទរូបនោះនឹងមានសម្បទាក្នុងការចូលរួមការជំនុំជម្រះក្ដីបាន (ពោលគឺ ជនជាប់ចោទមានសម្បទាមែននៅក្នុងពេលសមស្របណាមួយ)។ អាស្រ័យហេតុនេះ ដើមបណ្ដឹងសាទុក្ខ ពុំទទួលបានការគាំទ្រពីរឿងក្ដីទាំងឡាយ ដែលខ្លួនបានដកស្រង់ជាមូលដ្ឋានសម្រាប់សំណើដែលលើកឡើងថា ចុងបណ្ដឹងសាទុក្ខគួរត្រូវឃុំខ្លួន ឬ ដោះលែងឲ្យមានសេរីភាពដោយភ្ជាប់ជាមួយនឹងលក្ខខណ្ឌឲ្យបានតឹងរ៉ឹង[55]។

29. លើសពីនេះ ដូចចៅក្រមអន្តរជាតិនៃអង្គជំនុំជម្រះសាលាដំបូងបានចង្អុលបង្ហាញ[56] រឿងក្ដី Kovacević អាចមានលក្ខណៈប្លែកពីរឿងក្ដីបច្ចុប្បន្ននេះ ដោយហេតុថា ជនជាប់ចោទបានស្នើសុំឲ្យដោះលែងជាបណ្ដោះអាសន្ន ពីមន្ទីរឃុំឃាំង ដើម្បីផ្ដល់លទ្ធភាពដល់ខ្លួន នៅក្នុងការស្នើសុំឲ្យមានការព្យាបាលបញ្ហាវិកលចរិតលើរូបខ្លួន ហើយខុសពីកិច្ចដំណើរការនីតិវិធីនេះ ភាគីទាំងពីរបានឯកភាពគ្នាថា ជនជាប់ចោទខាងលើត្រូវការការព្យាបាលជាបន្ទាន់ នៅក្នុងមន្ទីរពេទ្យដើម្បីព្យាបាលសុខភាពផ្លូវចិត្ត[57]។

30. ចុងបណ្ដឹងសាទុក្ខនៅតែលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុស ដោយសារការខកខានពុំបានអនុវត្តវិធីសាស្ត្រ ដូចបានកំណត់នៅក្នុងវិធាននៃតុលាការព្រហ្មទណ្ឌអន្តរជាតិនោះទេ ដោយពិចារណាឃើញថា វិធានទាំងនេះសំដៅយ៉ាងជាក់លាក់លើ*ការលើកពេលនៃកិច្ចដំណើរការនីតិវិធី* ពុំមែនការផ្អាកកិច្ចដំណើរការនីតិវិធីឡើយ[58]។ ម៉្យាងវិញទៀត គ្មានចំណុចណាមួយនៅក្នុង

---

[55] សេចក្ដីសន្និដ្ឋានបន្ថែមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៣។

[56] សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៥។

[57] ករណី*រដ្ឋអាជ្ញា ទល់នឹង* Kovacević កថាខណ្ឌ ១០។

[58] សូមមើល វិធានស្ដីពីនីតិវិធី និងភស្តុតាងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ វិធាន ១៣៥។

សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្ហាញជាការរារាំងដើមបណ្តឹងសាទុក្ខ មិនឱ្យស្នើសុំតុលាការពិនិត្យឡើងវិញ លើស្ថានភាពរបស់ចុងបណ្តឹងសាទុក្ខឡើយ[59]។

31. អាស្រ័យហេតុនេះ សំណើសុំរក្សាចុងបណ្តឹងសាទុក្ខនៅក្នុងមន្ទីរឃុំឃាំង ពុំមានយុត្តិកម្ម ហើយជាការដាក់កំហិត និងដាក់ទណ្ឌកម្មដោយមិនត្រឹមត្រូវ។ មតិយោបល់ដែលបានលើកឡើងនៅក្នុងរឿងក្តី *Talić* គឺមានលក្ខណៈពាក់ព័ន្ធ និងត្រូវបានចុងបណ្តឹងសាទុក្ខយកមកធ្វើជាសំអាង។ មតិយោបល់នោះលើកឡើងថា វិធានការនីតិវិធី "មិនគួរមានលក្ខណៈខុសប្រក្រតី ឬ ហួសហេតុនោះឡើយ។ ប្រសិនបើវិធានការធូរស្រាលជាងនេះមួយអាចគ្រប់គ្រាន់យកមកប្រើប្រាស់បាន វិធានការនោះត្រូវយកមកអនុវត្ត"។ សំខាន់នោះគឺ យើងកត់សម្គាល់ឃើញថា ការឃុំខ្លួនបណ្តោះអាសន្ន មិនគួរយកមកប្រើប្រាស់ជាវិធានការដាក់ទណ្ឌកម្មឡើយ។ ហេតុដូច្នេះ យើងសូមសន្និដ្ឋានថា ចុងបណ្តឹងសាទុក្ខគួរត្រូវបានដោះលែងឱ្យមានសេរីភាពដោយគ្មានលក្ខខណ្ឌ។

**5.2 គ្មានកំហុសនៃអង្គហេតុ ដែលនាំឱ្យមានភាពមិនយុត្តិធម៌ និង/ឬ កំហុសលើអង្គច្បាប់នៅ ក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងទេ**

32. នៅពេលធ្វើសេចក្តីសម្រេចដោះលែងចុងបណ្តឹងសាទុក្ខពីមន្ទីរឃុំឃាំង ដោយពុំបង្គាប់ឱ្យសាកល្បងប្រើថ្នាំ Donepezil និង/ឬ ពុំទាមទារឱ្យមានការព្យាបាល ដើមបណ្តឹងសាទុក្ខមានកំហុសនៅពេលលើកឡើងថា អង្គជំនុំជម្រះសាលាដំបូង*ពុំយកចិត្តទុកដាក់*លើមតិយោបល់របស់អ្នកជំនាញ ដែលបានលើកឡើងថា វិធានការថែទាំ និងព្យាបាល អាចធ្វើឱ្យស្ថានភាពរបស់ចុងបណ្តឹងសាទុក្ខបានប្រសើរឡើង[60]។

33. យើងសូមសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងពិតជាបង្ហាញយ៉ាងច្បាស់ថា អង្គជំនុំជម្រះសាលាដំបូងបានយកមតិយោបល់របស់អ្នកជំនាញមកពិចារណាយ៉ាងល្អិតល្អន់ នៅពេលចេញសេចក្តីសម្រេច[61] ហើយការសម្រេចដូច្នេះ គឺជាការគោរពលើលទ្ធភាពនៃវិធានការទាំងឡាយ ដែលអាចធ្វើឱ្យស្ថានភាពរបស់ចុងបណ្តឹងសាទុក្ខ និងរោគសញ្ញាទាំងមូល មានភាពប្រសើរឡើងយ៉ាងពិតប្រាកដ។ វាជាអំណាចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការពិចារណា និងថ្លឹងថ្លែងភស្តុតាង

---

[59] ករណី*រដ្ឋអាជ្ញា ទល់នឹង Talić* កថាខណ្ឌ ២៣ ដកស្រង់ករណី *រដ្ឋអាជ្ញា ទល់នឹង Jokić* រឿងក្តី IT-02-53-PT សេចក្តីសម្រេចលើសំណើសុំដោះលែងជនជាប់ចោទ *Jokić* បណ្តោះអាសន្ន ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០២ កថាខណ្ឌ ១៨។

[60] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៥។ សេចក្តីសន្និដ្ឋានបន្ថែមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៩ (គូសបញ្ជាក់បន្ថែម)។

[61] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៦, ៥៣, ៦៥-៦៨ និង ៧១-៧៣។

ដែលមាននៅចំពោះមុខខ្លួន មុនពេលធ្វើសេចក្តីសម្រេច។ ជាពិសេស អង្គជំនុំជម្រះសាលាដំបូង បានពិចារណាលើភស្តុតាងទាំងអស់ដែលពាក់ព័ន្ធនឹងប្រសិទ្ធភាពនៃថ្នាំព្យាបាល ដែលបានស្នើឡើង ពោលគឺ ថ្នាំ Donepezil និងប្រសិទ្ធភាពនៃតិកិច្ចា។ អង្គជំនុំជម្រះសាលាដំបូងមានសិទ្ធិសន្និដ្ឋានថា ប្រសិនបើប្រយោជន៍ណាមួយបានកើតឡើងនោះ ប្រយោជន៍នោះនឹងមានរយៈពេលខ្លីតែប៉ុណ្ណោះ ដោយពុំអាចធ្វើឱ្យចុងបណ្តឹងសាទុក្ខមានសម្បទាក្នុងការចូលរួមសវនាការជំនុំជម្រះក្តីឡើយ[62]។ ឆន្ទានុសិទ្ធិនេះបានអនុវត្តដោយត្រឹមត្រូវ និងសមហេតុផល ផ្អែកទៅតាមភស្តុតាងទាំងឡាយដែលមានស្រាប់។

34. ទោះក្នុងករណីណាក៏ដោយ យុត្តិសាស្ត្រអន្តរជាតិបង្ហាញយ៉ាងច្បាស់ថា តុលាការមួយមិនតម្រូវឱ្យគោរពតាមសក្ខីកម្មរបស់អ្នកជំនាញឡើយ។ ឧទាហរណ៍ ក្រុមប្រឹក្សាជំនុំជម្រះពិសេសមួយលើឧក្រិដ្ឋកម្មធ្ងន់ធ្ងរ[63] បានលើកឡើងនៅក្នុងរឿងក្តី *Nahak* ថា៖

> "នៅក្នុងករណីសាក្សីជំនាញបានផ្តល់សក្ខីកម្ម តុលាការត្រូវសម្រេចថានឹងផ្តល់ទម្ងន់ប៉ុនណាលើសក្ខីកម្មរបស់សាក្សីជំនាញ។ ក៏ប៉ុន្តែ តុលាការពុំមានកាតព្វកិច្ចត្រូវគោរពតាមមតិយោបល់របស់អ្នកជំនាញចំពោះបញ្ហាសមត្ថកិច្ចឡើយ ពីព្រោះតែសេចក្តីសម្រេចពាក់ព័ន្ធនឹងបញ្ហាសមត្ថកិច្ចគឺជាសេចក្តីសម្រេចតាមផ្លូវច្បាប់ ពុំមែនជាសេចក្តីសម្រេចតាមលក្ខណៈវិទ្យាសាស្ត្រឡើយ"[64]។

35. ដើមបណ្តឹងសាទុក្ខបានលើកឡើងដោយមិនត្រឹមត្រូវថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះមិនបង្គាប់ឱ្យសាកល្បងប្រើថ្នាំ Donepezil បានធ្វើឡើងដោយផ្អែកលើមូលដ្ឋានថា ថ្នាំនេះពុំអាចរកបាននៅក្នុងប្រទេសកម្ពុជាទេ[65]។ ចុងបណ្តឹងសាទុក្ខបានចង្អុលបង្ហាញថា ការសម្រេចដូច្នេះពុំមែនជាហេតុផលតែមួយ ឬ កត្តាកំណត់តែមួយនៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះនោះឡើយ ដែលសេចក្តីសម្រេចនេះបានពិចារណាយ៉ាងហ្មត់ចត់លើមតិយោបល់របស់អ្នកជំនាញ ដូចបានគូសបញ្ជាក់នៅក្នុងចំណុចខាងក្រោម។

36. លោកសាស្ត្រាចារ្យ Campbell បានលើកឡើងនៅក្នុងភស្តុតាងថា លោកបានផ្តល់អនុសាសន៍ឱ្យសាកល្បងប្រើថ្នាំ Donepezil។ ក៏ប៉ុន្តែ លោកសាស្ត្រាចារ្យផ្តល់យោបល់ថា ថ្នាំនេះឃើញមានប្រសិទ្ធភាពលើមនុស្សប្រហែលតែមួយភាគបីប៉ុណ្ណោះ ដែលបានលេបថ្នាំនេះ ហើយវាអាច

---

[62] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៥៣។

[63] សាលាដំបូងរបស់ក្រុង Dili នៃប្រទេសទីម័រខាងកើត ក្រុមប្រឹក្សាជំនុំជម្រះពិសេសសម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរ។

[64] ករណី *រដ្ឋអាជ្ញា ទល់នឹង Nahak* រឿងក្តីលេខ 01A/2004 សំអាងហេតុ និងដីកាសម្រេចលើសម្បទារបស់ចុងចោទ Nahak ក្នុងការចូលរួមការជំនុំជម្រះក្តី ចុះថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០០៥ កថាខណ្ឌ ១២០។

[65] សេចក្តីសន្និដ្ឋានបន្ថែមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២១។

“ក៏ប៉ុន្តែ ពុំទំនងទេ”[66] ថា សមត្ថភាពខាងសតិបញ្ញានឹងមានភាពប្រសើរឡើងវិញច្រើននោះ។ ម្យ៉ាងវិញទៀត លោកបានលើកឡើងថា ការប្រសើរឡើងនេះទំនងជា “ពុំមានច្រើនទេ”[67]។ បន្ទាប់ពីនោះមក ស្ថានភាពរបស់ចុងបណ្តឹងសាទុក្ខនឹងបន្តធ្លាក់ចុះ[68]។ ចំពោះវិធីផ្សេងទៀតដែលអាចធ្វើឡើង ដើម្បីធ្វើឲ្យស្ថានភាពនេះប្រសើរជាងមុននោះ លោកបានលើកឡើងផងដែរថា “វាពុំទំនងនោះទេថា ការប្រែប្រួលណាមួយនឹង - ការប្រែប្រួលផ្នែកចិត្តសង្គមនឹងធ្វើឲ្យស្ថានភាពនេះប្រសើរឡើង និងធ្វើឲ្យស្មារតី ឬ សកម្មភាពប្រសើរឡើង”[69]។ អ្នកជំនាញផ្នែកវិកលចរិតបានឯកភាពស្រដៀងនេះផងដែរថា ថ្នាំ Donepezil នឹងត្រឹមតែធ្វើឲ្យមានការប្រសើរឡើងតិចតួចប៉ុណ្ណោះ ហើយការប្រសើរឡើងទាំងនេះ អាចកើតមានលើបុគ្គលមួយចំនួនតូចតែប៉ុណ្ណោះ ដែលបានលេបថ្នាំនេះ[70]។ អ្នកជំនាញក៏បានបង្ហាញនូវការព្រួយបារម្ភថា ផលប៉ះពាល់អាចកើតចេញពីថ្នាំនេះ និងភាពប្រសើរឡើងនេះអាចមានលក្ខណៈបណ្តោះអាសន្នតែប៉ុណ្ណោះ[71]។

37. នៅចុងក្រោយ សេចក្តីសម្រេចជាឯកច្ឆន្ទរបស់អង្គជំនុំជម្រះសាលាដំបូងដែលមិនបង្គាប់ឲ្យសាកល្បងប្រើថ្នាំគ្រាប់ Donepezil បានផ្តល់ហេតុផលយ៉ាងត្រឹមត្រូវ ហើយបានផ្អែកលើកត្តាមួយចំនួនផងដែរ ពោលគឺ លក្ខណៈវិវឌ្ឍទៅមុខនៃជំងឺ សេចក្តីសង្ឃឹមតិចតួចពីថ្នាំនេះដែលថា ភាពប្រសើរឡើងច្រើនលើស្ថានភាពរបស់ចុងបណ្តឹងសាទុក្ខនឹងមានលក្ខណៈបណ្តោះអាសន្ន ភាពលំបាកក្នុងការតាមដានការបើកថ្នាំឲ្យប្រើនៅក្នុងប្រទេសកម្ពុជា និងករណីដែលថា ការបន្ថយថ្នាំ Benzodiazepine ពុំមានប្រសិទ្ធភាពធ្វើឲ្យការចងចាំរបស់ចុងបណ្តឹងសាទុក្ខបានប្រសើរឡើងឡើយ[72]។

38. ហេតុដូច្នេះ សេចក្តីសម្រេចបង្គាប់មិនឲ្យដាក់លក្ខខណ្ឌលើចុងបណ្តឹងសាទុក្ខ នៅពេលដោះលែងឲ្យមានសេរីភាព ដូចជា ការព្យាបាល ឬ តិកិច្ឆា ពុំមែនជាកំហុសអង្គហេតុ ឬ ក៏ពុំមែនជាការអនុវត្តឆន្ទានុសិទ្ធិដោយមិនត្រឹមត្រូវដោយអង្គជំនុំជម្រះសាលាដំបូងឡើយ ពីព្រោះភ័ស្តុតាងបាន

---

[66] ប្រតិចារឹក ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១១ ទំព័រ ៩១-៩២។

[67] របាយការណ៍តាមដានរបស់លោកសាស្ត្រាចារ្យ Campbell កថាខណ្ឌ ៨(ii)។

[68] ប្រតិចារឹក ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១១ ទំព័រ ១៤០ និងប្រតិចារឹក ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១១ ទំព័រ ៦៦។

[69] ប្រតិចារឹក ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១១ ទំព័រ ៩៤។

[70] របាយការណ៍របស់អ្នកជំនាញផ្នែកវិកលចរិត កថាខណ្ឌ ៣៧។

[71] ប្រតិចារឹក ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ ទំព័រ ៧៥-៧៦។

[72] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៦ និងកថាខណ្ឌ ៥៣។ ការពិត អង្គជំនុំជម្រះសាលាដំបូងយោងដោយភ័ន្តច្រឡំលើការបន្ថយថ្នាំប្រឆាំងរោគចិត្ត នៅពេលការបន្ថយនេះបានធ្វើឡើង ក្រោយពីការបន្ថយថ្នាំ Benzodiazepine តែប៉ុណ្ណោះ។

បង្ហាញថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណា លើលក្ខណៈវិវឌ្ឍទៅមុខនៃស្ថានភាពរបស់ចុងបណ្តឹងសាទុក្ខ និងលទ្ធភាព ដែលថា ចុងបណ្តឹងសាទុក្ខអាចមានសម្បទាក្នុងការចូលរួមការជំនុំជម្រះក្តីវិញ។ ចៅក្រមអន្តរជាតិបានបង្ហាញជំហរដែលគួរឱ្យសោកស្តាយដូចតទៅ៖

> "អ្នកជំនាញទាំងអស់សុទ្ធតែយល់ឃើញដូចគ្នាថា បរិយាកាសដែលមានលក្ខណៈជំរុញសកម្មភាពលោកស្រី អៀង ធីរិទ្ធ គឺមានតែការដោះលែងគាត់ឱ្យវិលទៅកាន់គេហដ្ឋានគាត់វិញតែប៉ុណ្ណោះ។ ប៉ុន្តែចៅក្រមអន្តរជាតិពិចារណាឃើញថា ស្ថានភាពរបស់លោកស្រី អៀង ធីរិទ្ធ នឹងទំនងជាពុំមានភាពល្អប្រសើរឡើងវិញនោះទេ។ ទោះជាយ៉ាងណាក៏ដោយ <u>មិនចំពោះថាគេអនុវត្តវិធានការវេជ្ជសាស្ត្រ ឬ វិធានព្យាបាលផ្សេងណាមួយនោះទេ គ្មានវិធានការណាមួយក្នុងចំណោមវិធានការទាំងនេះ នឹងអាចផ្លាស់ប្តូរ ឬ ព្យាបាលកម្រិតជំងឺវង្វេងវង្វាន់ស្មារតីរបស់គាត់ក្នុងពេលបច្ចុប្បន្ន ប្រកបដោយប្រសិទ្ធភាពនោះទេ</u>។ អ្នកជំនាញបានគូសបញ្ជាក់ថា លោកស្រី អៀង ធីរិទ្ធ មានជំងឺវង្វេងវង្វាន់ស្មារតីដំណាក់កាលទី ៥ ក្នុងចំណោមដំណាក់ការទី ៧ ឬ "ដំណាក់កាលដំបូងនៃជំងឺវង្វេងវង្វាន់ស្មារតី៖ ការចុះខ្សោយសតិបញ្ញាកម្រិតធ្ងន់មធ្យម" និងស្ថានភាពនេះនឹងបន្តចុះដុនដាបជាលំដាប់"[73]។

39. ម្យ៉ាងវិញទៀត យើងខ្ញុំសូមសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាយ៉ាងត្រឹមត្រូវលើភ័ស្តុតាងរបស់អ្នកជំនាញ ពាក់ព័ន្ធនឹងផលប៉ះពាល់លើស្ថានភាពជនជាប់ចោទដែលកើតចេញពីការឃុំឃាំង និងលើករណីដែលថា ពុំមានអ្នកជំនាញណាម្នាក់បានពិចារណាឃើញថា មន្ទីរពេទ្យគឺជាបរិយាកាសចាំបាច់ ឬ សមរម្យសម្រាប់ជនជាប់ចោទឡើយ។ ក្នុងករណីនេះ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់ភ័ស្តុតាងពីលោកសាស្ត្រាចារ្យ Campbell ដែលបានបង្ហាញថា បរិយាកាសតានតឹងនៅក្នុងមន្ទីរឃុំឃាំង ត្រូវបានយល់ឃើញថាប៉ះពាល់ជាអវិជ្ជមានដល់ស្ថានភាពរបស់ចុងបណ្តឹងសាទុក្ខ។ នៅក្នុងរបាយការណ៍ដំបូង លោកសាស្ត្រាចារ្យបានលើកឡើងថា កត្តាមួយក្នុងចំណោមកត្តាទាំងនេះដែលបានប៉ះពាល់ដល់មុខងារសតិបញ្ញារបស់ចុងបណ្តឹងសាទុក្ខ គឺ "បរិយាកាសតានតឹងជុំវិញខ្លួន និងកម្លាំងចិត្ត"[74]។ នៅក្នុងពេលសវនាការបឋមស្តីពីសម្បទា ក្នុងការចូលរួមការជំនុំជម្រះក្តី លោកសាស្ត្រាចារ្យបានផ្តល់ភស្តុតាងថា លក្ខណៈវិវឌ្ឍទៅមុខនៃជំងឺរបស់ចុងបណ្តឹងសាទុក្ខ "ចាំបាច់ត្រូវធ្វើឱ្យស្របទៅនឹងកាលៈទេសៈរបស់លោកស្រីក្នុងរយៈពេលពី ១៨ ខែ ទៅ ២ ឆ្នាំ ដែលកាលៈទេសៈទាំងនេះ ឬ ការមិនមានកម្លាំងចិត្តពីខាងក្រៅសម្ពាធដែលលោកស្រីបានទទួលរងការជាប់ឃុំឃាំង នឹងបន្ថែមបន្ទុកលើមុខងារសតិបញ្ញា ពោលគឺ អារម្មណ៍របស់លោកស្រី

---

[73] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧២។

[74] របាយការណ៍របស់លោកសាស្ត្រាចារ្យ Campbell កថាខណ្ឌ ៣២។

ផងដែរ"[75]។ ទិដ្ឋភាពនេះត្រូវបានដើមបណ្ដឹងសាទុក្ខទទួលស្គាល់នៅពេលធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់ផងដែរ[76]។

40. អ្នកជំនាញផ្នែកវិកលចរិតក៏បានផ្ដល់យោបល់ផងដែរថា ការព្យាបាលគឺទំនងជាមានប្រសិទ្ធភាពយ៉ាងពិតប្រាកដលើស្ថានភាពរបស់ចុងបណ្ដឹងសាទុក្ខ ប្រសិនបើនៅក្នុងបរិយាកាសជុំវិញខ្លួនដែលពុំសូវតានតឹងជាងនេះ ពោលគឺមិនមែនការឃុំខ្លួននៅមន្ទីរឃុំឃាំង ឬ ការព្យាបាលនៅក្នុងមន្ទីរពេទ្យ[77]។ ឧទាហរណ៍ បណ្ឌិត Fazel បានលើកឡើងថា៖

> "មានវិធានការផ្សេងទៀតដែលអាចមានប្រយោជន៍ ប៉ុន្តែ ខ្ញុំគិតថា វិធានការទាំងនេះមានលក្ខណៈពិបាកអនុវត្តនៅក្នុងស្ថានភាពបច្ចុប្បន្ននេះ ពោលគឺ ការហាត់ប្រាណដែលមនុស្សខ្លះគិតថាមានប្រយោជន៍ ហើយនិងសកម្មភាពដែលជំរុញអារម្មណ៍របស់លោកស្រី ដែលគេហៅថាជាការដាស់អារម្មណ៍។ ខ្ញុំគិតថា បើនិយាយឱ្យសាមញ្ញ គឺសកម្មភាព សកម្មភាពទាំងឡាយ ជារឿយៗ ក្នុងលក្ខណៈជាក្រុម ដែលជំរុញឱ្យបុគ្គលម្នាក់គិត និងផ្ដល់ហេតុផល និងប្រើប្រាស់ការចងចាំរបស់ខ្លួន និងប្រើប្រាស់សកម្មភាពពាក់ព័ន្ធផ្សេងទៀត"[78]។

41. លើសពីនេះ យើងគួរកត់សម្គាល់ឃើញថា ទោះបីជាចុងបណ្ដឹងសាទុក្ខបានសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យជាច្រើនលើកច្រើនសាក្នុងរយៈពេលឃុំខ្លួន ៤ ឆ្នាំ ដោយសារបញ្ហាសុខភាពរាងកាយក៏ដោយ ក៏ពុំមានការស្នើឡើងថា ចុងបណ្ដឹងសាទុក្ខគួរទទួលព្យាបាលជំងឺវង្វេងវង្វាន់ស្មារតីរបស់ខ្លួននៅក្នុងមន្ទីរពេទ្យឡើយ។ ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូល នឹងឯកភាពជាមួយនឹងដើមបណ្ដឹងសាទុក្ខលើភាពចាំបាច់ក្នុងការ "ប្រើប្រាស់ឱ្យអស់លទ្ធភាពជាមុនសិន"[79] នោះយើងអាចទាញចេញពីចំណុចនេះថា ការដោះលែងឱ្យមានសេរីភាពពីការឃុំខ្លួន ដែលមានបរិយាកាសតានតឹង គឺជាការចាំបាច់ ដើម្បីផ្ដល់គ្រប់លទ្ធភាពទាំងអស់ ធ្វើឱ្យស្ថានភាពរបស់ចុងបណ្ដឹងសាទុក្ខប្រសើរឡើង។ កម្លាំងចិត្តបន្ថែមដល់ចុងបណ្ដឹងសាទុក្ខតាមរយៈរូបថត រូបភាពខ្សែវីដេអូ និងឯកសារ ពុំចាំបាច់ទាមទារឱ្យចូលសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យឡើយ។ ការលើកទឹកចិត្តទាំងនេះអាចទទួលបាននៅក្នុងបរិយាកាសនៅផ្ទះ។

---

[75] ប្រតិចារឹកចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១១ ទំព័រ ៦០។ សូមមើលផងដែរ ប្រតិចារឹក ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១១ ទំព័រ ១០៦-១០៧។

[76] ប្រតិចារឹក ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ ទំព័រ ១០៨។

[77] ប្រតិចារឹក ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១១ ទំព័រ ១១២-១១៣។

[78] ដូចខាងលើ។

[79] សេចក្ដីសន្និដ្ឋានបន្ថែមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៥។ ប្រតិចារឹក ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ ទំព័រ ១០៩។

### 5.3 មានកំហុសឆ្គងផ្នែកអង្គច្បាប់ ឬ ឆន្ទានុសិទ្ធិក្នុងសេចក្តីសម្រេចស្តីពីរបៀបបន្តកិច្ចដំណើរការនីតិវិធី នៅពេលគ្មានសំឡេងភាគច្រើន

42. អង្គជំនុំជម្រះតុលាការកំពូល គប្បីបដិសេធអំណះអំណាងរបស់ម្ចាស់បណ្តឹងសាទុក្ខ ដែលលើកឡើងថាជំហររបស់ចៅក្រមអន្តរជាតិលើបញ្ហាសំខាន់ នៃផលវិបាកនៃភាពគ្មានសម្បទារបស់ជនជាប់ចោទមានប្រៀបលើចៅក្រមជាតិទាំងបីរូប គឺជាកំហុសឆ្គងផ្នែកអង្គច្បាប់ និង/ឬ ការអនុវត្តឆន្ទានុសិទ្ធិ[80]។

43. ចំណុចដែលពាក់ព័ន្ធ និងសំខាន់ដែលគួរឲ្យកត់សម្គាល់ គឺអង្គជំនុំជម្រះសាលាដំបូងបានសម្រេចជាឯកច្ឆន្ទរួចមកហើយ អំពីថាតើចុងបណ្តឹងសាទុក្ខគប្បីត្រូវបានដោះលែងពីមន្ទីរឃុំឃាំង ឬយ៉ាងណា។ ចៅក្រមអន្តរជាតិទាំងពីររូបយល់ឃើញថា ចុងបណ្តឹងសាទុក្ខមិនគប្បីបន្តនៅជាប់ឃុំឃាំងជាបណ្តោះអាសន្នតទៅទៀតនោះទេ[81]។ មិនតែប៉ុណ្ណោះ អង្គជំនុំជម្រះសាលាដំបូង ទាំងមូល (មិនមែនមតិភាគតិច) បានសម្រេចថា ក្នុងករណីរកសេចក្តីសម្រេចដោយមតិភាគច្រើនមិនបានស្តីពីផលវិបាកនៃភាពគ្មានសម្បទារបស់ចុងបណ្តឹងសាទុក្ខ គាត់មិនត្រូវនៅជាប់ឃុំបន្តនៅមន្ទីរឃុំឃាំងនៃ អ.វ.ត.ក នោះទេ[82] និងគប្បីត្រូវបានដោះលែងដោយឥតលក្ខខណ្ឌ[83]។

44. ក្នុងករណីរកសេចក្តីសម្រេចដោយមតិភាគច្រើនមិនបាន និងគ្មានការណែនាំពីច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង[84] អង្គជំនុំជម្រះសាលាដំបូង គប្បីអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ធ្វើយ៉ាងណាឲ្យបានជាប្រយោជន៍ដល់ចុងបណ្តឹងសាទុក្ខ។ អង្គជំនុំជម្រះសាលាដំបូង បានសម្រេចត្រឹមត្រូវរួចហើយថា រវាងការឃុំខ្លួនដោយបង្ខំនៅក្នុងមន្ទីរពេទ្យ និងការដោះលែងដោយឥតលក្ខខណ្ឌ ការដោះលែងដោយឥតលក្ខខណ្ឌគឺបានជាប្រយោជន៍ដល់ជនជាប់ចោទ ដោយអនុលោមទៅតាមគោលការណ៍សច្ចធារណ៍និរទោស គោលការណ៍សេរីភាពគឺជាបទដ្ឋាន និងគោលការណ៍ការឃុំខ្លួន ឬការបង្ខំឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យ គឺជាការលើកលែង[85]។

45. ឧទាហរណ៍មួយដែលបញ្ជាក់ថា អង្គជំនុំជម្រះមិនអាចរកសំឡេងភាគច្រើនដាច់ខាតបាន (ស្តីពីបញ្ហានៃអាជ្ញាយុកាលនៃបទល្មើសក្រោមច្បាប់ជាតិ ក្នុងសំណុំរឿង ០០១) បានកើតមានឡើងម្តង

---

[80] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៧-១៨។

[81] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៧។

[82] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៧៧។

[83] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨០-៨១។

[84] មាត្រា ៤ នៃកិច្ចព្រមព្រៀង ពុំមានចែងអំពីបច្ច័យនៃការរកសំឡេងភាគច្រើនដាច់ខាតមិនបាននោះទេ។

[85] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៨០។

រួចមកហើយក្នុងរឿងក្តី *ឌុច*។ នៅពេលនោះ អង្គជំនុំជម្រះបានសន្និដ្ឋានថា ការពុំអាចរកសំឡេងភាគច្រើនដែលចាំបាច់បាន "គឺបង្កើតបានជាឧបសគ្គរារាំងដល់ការបន្តការចោទប្រកាន់លើជនជាប់ចោទ អំពីបទល្មើសក្រោមច្បាប់ជាតិនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[86] ដូច្នេះសម្រេចតម្កល់ការបកស្រាយដែលផ្តល់ផលប្រយោជន៍ដល់ជនជាប់ចោទ។

46. ដូច្នេះ យោងតាមសំអាងហេតុទាំងនេះ យើងខ្ញុំសូមអះអាងថា ចុងចម្លើយសាទុក្ខគប្បីត្រូវបានដោះលែងដោយឥតលក្ខខណ្ឌ។

**5.4 ផ្ទុយទៅនឹងសារណារបស់ចុងបណ្តឹងសាទុក្ខ ប្រសិនបើសេចក្តីសម្រេចត្រូវធ្វើឱ្យទៅជាមោឃៈ ឬធ្វើវិសោធនកម្ម នោះចុងចម្លើយសាទុក្ខគប្បីត្រូវបានដោះលែងឱ្យរួចពីការឃុំខ្លួនដដែល គ្រាន់តែត្រូវដាក់ឱ្យស្ថិតក្រោមលក្ខខណ្ឌមួយចំនួន**

47. ជំហរជាចម្បងរបស់ចុងបណ្តឹងសាទុក្ខ គឺថាគាត់គប្បីត្រូវបានដោះលែងដោយឥតលក្ខខណ្ឌ។ ក្នុងករណីដែលអង្គជំនុំជម្រះតុលាការកំពូលមិនបានបង្គាប់ដូច្នេះ ដើម្បីយុត្តិធម៌ ចុងបណ្តឹងសាទុក្ខគប្បីត្រូវបានដោះលែង ដោយគ្រាន់តែត្រូវដាក់ឱ្យស្ថិតក្រោមលក្ខខណ្ឌមួយចំនួនដូចខាងក្រោម៖

ក) វិលទៅរស់នៅលំនៅដ្ឋានមួយ(ច្រើន) ដោយត្រូវជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូង ដោយឈរលើមូលដ្ឋាននៃ"ការលាក់ការណ៍សម្ងាត់បំផុត"។

ខ) ទទួលការព្យាបាលណាមួយទៅតាមសេចក្តីបង្គាប់របស់តុលាការ សម្រាប់រយៈពេលកំណត់ច្បាស់លាស់ណាមួយ ដោយបន្ទាប់ពីរយៈនោះ គប្បីមានការវាយតម្លៃដោយឯករាជ្យលើស្ថានភាពផ្លូវចិត្តរបស់គាត់ ដោយត្រូវធ្វើឡើងដោយអ្នកជំនាញមួយរូប ដែលពុំធ្លាប់ពាក់ព័ន្ធនឹងការព្យាបាលណាមួយក្នុងពេលបច្ចុប្បន្ន។

គ) ត្រូវទទួលបានសេវាការពារសន្តិសុខ ដោយអនុលោមទៅតាមមាត្រា ២៤ នៃកិច្ចព្រមព្រៀង សម្រាប់រយៈពេលនៃការសម្រាកព្យាបាលនោះ។

## VI សេចក្តីសន្និដ្ឋាន

48. ដោយសេចក្តីគោរព ចុងបណ្តឹងសាទុក្ខ សូមស្នើឱ្យអង្គជំនុំជម្រះសាលាដំបូង៖

ក) អនុញ្ញាតឱ្យមានសវនាការផ្ទាល់មាត់លើបណ្តឹងសាទុក្ខនេះ

---

[86] សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អវតក/អជសដ អជសដ សេចក្តីសម្រេចស្តីពីអញ្ញត្រកម្មរបស់មេធាវីការពារក្តីពាក់ព័ន្ធនឹងអាជ្ញាយុកាលនៃបទល្មើសជាតិ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ ឯកសារ លេខ E ១៨៧ កថាខណ្ឌ ៥៦។

ខ) បដិសេធបណ្ដឹងសាទុក្ខចោលទាំងស្រុង ដោះលែងចុងបណ្ដឹងសាទុក្ខដោយឥតលក្ខខណ្ឌ និងបង្គាប់ថាការផ្អាកនីតិវិធីគប្បីឈានទៅរកការបញ្ឈប់ ឬបញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំងលើរូបគាត់។

គ) ឬជម្រើសមួយទៀតគឺសូមឲ្យដោះលែងចុងបណ្ដឹងសាទុក្ខ ដោយមានលក្ខខណ្ឌដូចមានរៀបរាប់ខាងលើ និងបង្គាប់ឲ្យមានការពិនិត្យឡើងវិញបន្ថែមមួយលើស្ថានភាពគាត់ ដោយមិនឲ្យលើសពីរយៈពេលប្រាំមួយខែ ដោយត្រូវធ្វើឡើងដោយអ្នកជំនាញមួយរូបដែលឯករាជ្យក្រៅពីវេជ្ជបណ្ឌិតដែលកំពុងព្យាបាលគាត់។

| ភាគី | កាលបរិច្ឆេទ | ឈ្មោះមេធាវី | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|---|
| សហមេធាវីរបស់ អៀង ធីរិទ្ធ | ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ | ផាត់ ពៅស៊ាង<br>Diana ELLIS, QC | ភ្នំពេញ | |